# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :......៤២៩/២០......ក.ប/ប្រ.ក.ខ.ល

## ប្រកាស

## ស្តីពី

## ការពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី៥ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

## សម្រេច

**ប្រការ១ .-**

កម្មករនិយោជិតខ្មែរទាំងពីរភេទ ដែលប្រកបមុខរបរណាមួយនៅក្នុងរោងចក្រ សហគ្រាសដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ត្រូវឆ្លងការពិនិត្យកាយសម្បទា។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២ ._**

មុនពេលប្រកបមុខរបរ កម្មករនិយោជិតខ្មែរត្រូវទៅពិនិត្យកាយសម្បទានៅនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬទៅពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលណាមួយដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងជាដៃគូរបស់នាយកដ្ឋានពេទ្យការងារ។

**ប្រការ៣ ._**

វិញ្ញាបនបត្រពិនិត្យកាយសម្បទាត្រូវចេញដោយនាយកដ្ឋានពេទ្យការងារ ដែលជាអង្គភាពទទួលបន្ទុកពិនិត្យ ប្រមូល និងគ្រប់គ្រងទិន្នន័យពីការពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរទូទាំងប្រទេស ដើម្បីធ្វើជាមូលដ្ឋានក្នុងការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

ក្នុងករណីដែលកម្មករនិយោជិតពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាលរាជធានី ខេត្ត និយោជកត្រូវស្នើសុំការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាពីនាយកដ្ឋានពេទ្យការងារ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយភ្ជាប់មកជាមួយនូវលទ្ធផលពិនិត្យសុខភាពរបស់កម្មករនិយោជិតដែលមានសុពលភាពមិនលើសពី ៦ (ប្រាំមួយ) ខែ។

រាល់លទ្ធផលនៃការពិនិត្យរបស់កម្មករនិយោជិតត្រូវរក្សាជាការសម្ងាត់។

**ប្រការ៤ ._**

សាមីជនដែលមកពិនិត្យកាយសម្បទា ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រមុខរបរកម្មករនិយោជិតខ្មែរចំនួន ១(មួយ)ច្បាប់ និងច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬសៀវភៅគ្រួសារចំនួន ១(មួយ)ច្បាប់។

**ប្រការ៥ ._**

កម្មករនិយោជិតនៃរោងចក្រ សហគ្រាស ត្រូវមកពិនិត្យកាយសម្បទារៀងរាល់ ២(ពីរ)ឆ្នាំ លើកលែងតែមុខរបរ ឬមុខជំនាញវិជ្ជាជីវៈ ដែលតម្រូវឱ្យពិនិត្យកាយសម្បទាជាពិសេស។ ការពិនិត្យកាយសម្បទា ត្រូវពិនិត្យជាលក្ខណៈពិសេសថែមទៀត តាមមុខជំនាញវិជ្ជាជីវៈ ឬមុខរបរប្រកបដោយគ្រោះថ្នាក់ខ្ពស់។

ក្រោយពេលធ្វើការពិនិត្យកាយសម្បទាបានសព្វគ្រប់ និងត្រឹមត្រូវ នាយកដ្ឋានពេទ្យការងារចេញវិញ្ញាបនបត្រពិនិត្យកាយសម្បទាជូនកម្មករនិយោជិតដើម្បីប្រើប្រាស់ជាផ្លូវការ។

**ប្រការ៦ ._**

ការចំណាយក្នុងការពិនិត្យកាយសម្បទា ឬពិនិត្យសុខភាពនិងការស្នើសុំបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទារបស់កម្មករនិយោជិត ជាបន្ទុករបស់និយោជក។

**ប្រការ៧ ._**

នៅពេលកម្មករនិយោជិតប្តូរការងារ ឬមុខរបរ ដែលមានលក្ខខណ្ឌការងារខុសពីការងារ ឬមុខរបរដើម ឬប្តូរការងារទៅរោងចក្រ សហគ្រាសថ្មី កម្មករនិយោជិតត្រូវពិនិត្យកាយសម្បទាឡើងវិញឱ្យបានសមស្របនឹងការងារ ឬមុខរបរថ្មីនោះ។

**ប្រការ៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៩
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ